# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
លេខ ៥៤២ ថទ.៣៤១-៩៩

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោកប្រធានតុលាការគ្រប់ជាន់ថ្នាក់**

**សូមជ្រាប។**

**កម្មវត្ថុ:** ការបន្តនិរន្តរភាពនៃការបញ្ជូនសេចក្ដីចម្លងសាលក្រម ឬ សាលដីកាព្រហ្មទណ្ឌស្ថាពរមកក្រសួងយុត្តិធម៌ដើម្បីរៀបចំបញ្ជីថ្កោលទោស ។

តាមកម្មវត្ថុខាងលើ សូមលោកប្រធានចាត់ការបញ្ជូនជាបន្តនូវសេចក្ដីចម្លងសាលក្រម ឬ សាលដីកាព្រហ្មទណ្ឌស្ថាពរមកក្រសួងយុត្តិធម៌ឱ្យបានទៀងទាត់ ដោយអនុលោមតាមខ្លឹមសារនៃលិខិតលេខ២៩៨.ថទ.៣៤១៤-៩៨ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ ដែលក្រសួងយុត្តិធម៌បានផ្ញើជូនតុលាការគ្រប់ជាន់ថ្នាក់រួចហើយ ដូចមានជូនជាប់មកជាមួយនេះស្រាប់ ។

សូមជម្រាបថា តុលាការមិនត្រូវខកខានមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់អំពីសាវតាជាតិរបស់ទណ្ឌិតក្នុងសាលក្រមឬសាលដីការបស់តុលាការ ដោយសារមូលហេតុជនល្មើសគេចខ្លួនបាត់នោះទេ ពីព្រោះជនល្មើសគេចខ្លួនបាត់មានពីរប្រភេទ៖

**ប្រភេទទី១** គឺជនល្មើសគេចខ្លួនបាត់ ប៉ុន្តែមានសាវតាជាតិគ្រប់គ្រាន់ ។ ជនល្មើសគេចខ្លួនបាត់ប្រភេទទី១នេះទើបតុលាការមានសិទ្ធិដាក់ជំនុំជម្រះសម្រេចសេចក្ដីកំបាំងមុខតាមច្បាប់បាន ។

**ប្រភេទទី២** គឺជនល្មើសដែលគេចខ្លួនបាត់គ្មានសាវតាជាតិ ។ ជនល្មើសប្រភេទនេះព្រះរាជអាជ្ញាត្រូវសម្រេចបង្អង់បណ្ដឹងអាជ្ញា ហើយមិនអាចសម្រេចចោទប្រកាន់ជូនទៅតុលាការជំនុំជម្រះសម្រេចសេចក្ដីកំបាំងមុខបានទេ លើកលែងតែអញ្ញាតជនដែលបានប្រព្រឹត្តបទល្មើសជលផល រុក្ខាប្រមាញ់ គយនិងពន្ធដារ ។

ចំពោះសំណុំឯកសារទាក់ទងនឹងរឿងព្រហ្មទណ្ឌដែលគ្មានកំណត់អំពីសាវតាជាតិរបស់ជនល្មើស អយ្យការនិងតុលាការត្រូវណែនាំឱ្យនគរបាលយុត្តិធម៌ស្រាវជ្រាវនិងកំណត់អំពីសាវតាជាតិនេះឱ្យបានច្បាស់លាស់ ។

ក្រសួងមានសុទិដ្ឋិនិយមនឹងសង្ឃឹមថា លោកប្រធានតុលាការគ្រប់ជាន់ថ្នាក់នឹងយកចិត្តទុកដាក់ធ្វើការងារនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ជូនក្រសួង ដើម្បីរួមចំណែកទទួលខុសត្រូវក្នុងការចេញលិខិតថ្កោលទោសជូនប្រជាពលរដ្ឋនិងអង្គការរដ្ឋផ្សេងៗ យកទៅប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមច្បាប់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩

**រដ្ឋមន្ត្រី**

**អ៊ុក វីធុន**